01490681

**Declassified to Public**
**08 April 2021**

D251

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jun-2017, 14:40
CMS/CFO: Sann Rada

**លេខសំណុំរឿង៖ ០០៣/០៧-០៩-០៩/អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ៖ **ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០១៧**

ភាសា៖ **អង់គ្លេស [ឯកសារដើម]**

ចំណាត់ថ្នាក់ឯកសារ៖ **សម្ងាត់**

---

# សេចក្តីសម្រេចរួមលើសំណើរបស់ មាស មុត សុំឲ្យបំពេញកិច្ចស៊ើបសួរនាក់ទង ការប្រើប្រាស់ជាសក្ខានុពលនៃភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម

---

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត៖**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Yiqiang LIU
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

# I. ប្រវត្តិនីតិវិធី

1. ការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះត្រូវបានចុះបញ្ជីកាលពីថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

2. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ខ្ញុំបានចេញសេចក្តីណែនាំដល់អ្នកស៊ើបអង្កេតទាំងអស់នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ស្តីពីនីតិវិធីដែលត្រូវអនុវត្តតាម នៅពេលធ្វើទំនាក់ទំនងបឋមជាមួយសាក្សីសក្តានុពល ("ការវាយតម្លៃ") និងការអនុវត្តការស្តាប់ចម្លើយជាផ្លូវការរបស់សាក្សី[1]។

3. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ ខ្ញុំបានចោទប្រកាន់ មាស មុត *ជាអាទិ៍* ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទារុណកម្មនៅតាមមន្ទីរសន្តិសុខនានា ជាពិសេសនៅមន្ទីរ ស-២១[2]។

4. នៅក្នុងខែ មករា និងខែ កុម្ភៈ ឆ្នាំ ២០១៦ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស Stephen Owen Tedder ("អ្នកស៊ើបអង្កេត") បានជួប និងស្តាប់ចម្លើយសាក្សី ម៉ែន ធារី[3] ឈុំ យ៉ា[4] ព្រំ ម៉ុន[5] កែវ សារួន[6] (ហៅជារួមថា "សាក្សី")។ កិច្ចស៊ើបសួរទាំងនេះត្រូវបានកត់ត្រានៅក្នុងកំណត់

---

[1] សំណុំរឿង ០០៣ ឯកសារ D157 *អនុស្សរណៈពី ស.ច.ស.អ ជូនចំពោះអ្នកស៊ើបអង្កេតទាំងអស់នៃ ក.ស.ច.ស ទាក់ទងនឹង "ការណែនាំស្តីពីការវាយតម្លៃដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដទៃទៀត និងស្តីពីទម្រង់នៃកំណត់ហេតុជាលាយលក្ខណ៍អក្សរ"* ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០១៥។

[2] សំណុំរឿង ០០៣ ឯកសារ D174 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត* ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ ទំព័រ ៤-៥។

[3] សំណុំរឿង ០០៣ ឯកសារ D114/164 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែន ធារី* ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៦ ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែន ធារី")។

[4] សំណុំរឿង ០០៣ ឯកសារ D114/167 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ យ៉ា* ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៦។

[5] សំណុំរឿង ០០៣ ឯកសារ D114/170 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន* ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន")។

[6] សំណុំរឿង ០០៣ ឯកសារ D114/171 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ សារួន* ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ ("កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ សារួន")។ ឈ្មោះរបស់សាក្សីជាភាសាអង់គ្លេសត្រូវបានសរសេរជា Keo Saruon នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី។

ហេតុនៃកិច្ចស៊ើបសួរ (“កំណត់ហេតុនៃកិច្ចស៊ើបសួរ”) ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ (“D114/174”) និងថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ (“D114/184”)[7]។

5. នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ខ្ញុំបានជូនដំណឹងដល់ភាគីទាំងអស់ថា ខ្ញុំយល់ឃើញថា ការស៊ើបសួរប្រឆាំង មាស មុត បានបិទបញ្ចប់ ដោយភាគីទាំងអស់មានរយៈពេល ៣០ ថ្ងៃ សម្រាប់ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម និងកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*នៃវិធានផ្ទៃក្នុង [8]។

6. នៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៧ មេធាវីការពារក្តីរបស់ មាស មុត (“មេធាវីការពារក្តី”) បានដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកព័ត៌មានបន្ថែមទាក់ទងនឹងការប្រើប្រាស់ជាសក្ខានុពលនៃភ័ស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ដើម្បីកំណត់អត្តសញ្ញាណ ស្វែងរក និងស្តាប់ចម្លើយសាក្សី (“សំណើទីមួយ”)[9]។

7. នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧ មេធាវីការពារក្តីបានដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកព័ត៌មានទាក់ទងនឹងការទំនាក់ទំនងជាមួយសាក្សី ម៉ែន ធារី ដោយមិនមានកំណត់ត្រា និងដើម្បីពិនិត្យកែប្រែកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់គាត់ (“កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី”) (“សំណើទីពីរ”)[10]។

---

[7] សំណុំរឿង ០០៣ ឯកសារ D114/174 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ (“D114/174”) ទំព័រ ៣-៤។ សំណុំរឿង ០០៣ ឯកសារ D114/184 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ (“D114/184”) ទំព័រ ២-៣។

[8] សំណុំរឿង ០០៣ ឯកសារ D225 *សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត* ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧។ សំណុំរឿង ០០៣ ឯកសារ D226 *ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន* ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧។

[9] សំណុំរឿង ០០៣ ឯកសារ D227 *សំណើរបស់ មាស មុត សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងឯកសារ D114/174, D114/184 និងការស្តាប់ចម្លើយសាក្សីដែលពាក់ព័ន្ធ និងការប្រើប្រាស់ភ័ស្តុតាងសក្ខានុពលដែលទទួលបានតាមរយៈការធ្វើទារុណកម្ម* ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៧។

[10] សំណុំរឿង ០០៣ ឯកសារ D229 *សំណើរបស់ មាស មុត សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងការទំនាក់ទំនងជាមួយសាក្សីដោយមិនមានកំណត់ត្រា និងសំណើសុំឱ្យពិនិត្យកែប្រែកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី* ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧។

## II. សារណា

### ក. សំណើទីមួយ

8. មេធាវីការពារក្តីស្នើសុំឲ្យ ស.ច.ស ស៊ើបអង្កេតលើកាលៈទេសៈ ដែល ក.ស.ច.ស បានកំណត់អត្តសញ្ញាណ ស្វែងរក និងស្តាប់ចម្លើយសាក្សី ដោយសំណើរបស់ខ្លួនសំអាងលើចម្លើយដែលបានធ្វើឡើងនៅក្នុងកំណត់ហេតុនៃកិច្ចស៊ើបសួរ ដែលសាក្សីត្រូវបានកំណត់អត្តសញ្ញាណ តាមរយៈលទ្ធផលនៃការព្យាយាមរបស់អ្នកស៊ើបអង្កេតក្នុងការស្វែងរកសមាជិកគ្រួសារជិតបំផុតដែលបានរៀបរាប់នៅក្នុងជីវប្រវត្តិពី ស-២១ របស់កម្មាភិបាលដែលត្រូវបានបោសសម្អាតនៅខេត្តក្រចេះចាប់ពីខែ វិច្ឆិកា ឆ្នាំ ១៩៧៨[11]។

9. មេធាវីការពារក្តីយល់ឃើញថា កិច្ចស៊ើបសួរដែលបានស្នើសុំ មានភាពចាំបាច់ដើម្បីកំណត់៖

ក. ថាតើអ្នកស៊ើបអង្កេតបានសំអាងដោយមិនត្រឹមត្រូវលើភ័ស្តុតាង ដែល *"ទទួលបានតាមរយៈការធ្វើទារុណកម្ម"* ដូចជាចម្លើយសារភាព ឬជីវប្រវត្តិពី ស-២១ ដើម្បីស្តាប់ចម្លើយសាក្សី ដែលនឹងធ្វើឲ្យភ័ស្តុតាងរបស់សាក្សីនោះ មិនអាចជឿជាក់បាន ហើយប្រសិនបើដូច្នេះមែន ត្រូវមានការទាមទារឲ្យមានដំណោះស្រាយសមស្រប និងអាចត្រូវបានធ្វើមោឃភាព[12] និង

ខ. ថាតើអ្នកស៊ើបអង្កេតគ្រាន់តែស្វែងរកសាក្សីទាំងនោះ ដោយសារតែព័ត៌មានដែលបានផ្តល់ដោយកម្មាភិបាលដែលត្រូវបានបោសសម្អាតនៅក្នុងជីវប្រវត្តិពី ស-២១ ដែលអាចធ្វើឲ្យភ័ស្តុតាងរបស់សាក្សីទាំងនោះ ជា *"ភ័ស្តុតាងទទួលបានតាមរយៈការធ្វើទារុណកម្ម"* ដែលនឹងរារាំង ក.ស.ច.ស មិនឲ្យសំអាងលើភ័ស្តុតាងនោះ ហើយប្រសិនបើដូច្នេះមែន ត្រូវមានការទាមទារឲ្យមានដំណោះស្រាយសមស្រប និងអាចត្រូវបានធ្វើមោឃភាព[13]។

---

[11] សំណើទីមួយ កថាខណ្ឌ ៤, ៨, ១២, ១៨។ ឯកសារ D114/174 ទំព័រ ៣។ ឯកសារ D114/184 ទំព័រ ២។

[12] *ដូចដើងទំព័រខាងលើ* ទំព័រ ១ កថាខណ្ឌ ១៤, ១៨។

[13] *ដូចដើងទំព័រខាងលើ* ទំព័រ ១ កថាខណ្ឌ ១៩, ២០។

10. ជាពិសេស មេធាវីការពារក្ដីស្នើសុំនូវព័ត៌មានដូចខាងក្រោម៖

ក. ព័ត៌មានលម្អិតនៃឯកសារដែលអ្នកស៊ើបអង្កេតបានប្រើដើម្បីកំណត់អត្តសញ្ញាណសាក្សី ហើយប្រសិនបើចាំបាច់ បញ្ជាក់ពីការដាក់ឯកសារទាំងនោះទៅក្នុងសំណុំរឿង។

ខ. ការបញ្ជាក់បំភ្លឺថាតើព័ត៌មានទាក់ទងនឹងសាក្សីទាំងនោះ កើតចេញតែពីជីវប្រវត្តិពីមន្ទីរ ស-២១ ដែរឬយ៉ាងណា ដែលយោងដោយឯកសារ D114/174 និង D114/184 ឬថាតើ ក.ស.ច.ស បានដឹងពីសាក្សីទាំងនោះពីឯកសារផ្សេងទៀត ដែលនៅក្នុងសំណុំរឿងដែល មេធាវីការពារក្ដីបានស្នើសុំព័ត៌មានលម្អិតនៃឯកសារទាំងនោះ ហើយប្រសិនបើចាំបាច់ បញ្ជាក់ពីការដាក់ឯកសារទាំងនោះទៅក្នុងសំណុំរឿង និង

គ. ព័ត៌មានលម្អិតនៃឯកសារណាមួយដែលទាក់ទងទៅនឹងការចាប់ខ្លួនសាច់ញាតិរបស់សាក្សី ដែលអ្នកស៊ើបអង្កេតបានបង្ហាញដល់សាក្សីនៅមុនពេល ឬក្នុងអំឡុងពេលនៃការទាក់ទង លើកដំបូង និងការស្ដាប់ចម្លើយរបស់គាត់[14]។

11. មេធាវីការពារក្ដីលើកឡើងថា ខណៈពេលដែល ក.ស.ច.ស បានលើកឡើងនាពេលកន្លងមក ថា ព័ត៌មានក្នុងឯកសារដែលទទួលបានតាមរយៈការធ្វើទារុណកម្ម អាចត្រូវបានប្រើប្រាស់ជា តម្រុយនៃភ័ស្ដុតាងនោះ គោលជំហរនេះផ្ទុយស្រឡះពីយុត្តិសាស្ត្រក្រោយមករបស់ អ.វ.ត.ក។ ព័ត៌មាននៅក្នុងជីវប្រវត្តិពី ស-២១ ដែលអ្នកស៊ើបអង្កេតបានប្រើប្រាស់ ក៏មិនមានចំណារ របស់អ្នកសួរចម្លើយ ឬថ្នាក់លើ ឬព័ត៌មានស្ដីពីអត្តសញ្ញាណរបស់អ្នកជាប់ឃុំ ឬកាលបរិច្ឆេទ ចាប់ខ្លួន ការឃុំឃាំង ឬការសម្លាប់ដែលត្រូវបានកត់ត្រាទុកនៅពេលចុះឈ្មោះ ឬនៅលើទំព័រ មុខនៃចម្លើយសារភាពឡើយ ដែលព័ត៌មានប្រភេទនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងចាត់ ទុកថាមិនអាចទទួលយកបានក្នុងពេលកន្លងមក[15]។ លើសពីនេះទៀត ភ័ស្ដុតាងដែលទទួល បានតាមរយៈការធ្វើទារុណកម្ម ដូចជា សំណួរនានាដែលផ្អែកលើចម្លើយសារភាពបានពីមន្ទីរ

[14] សំណើទីមួយ កថាខណ្ឌ ១២។

[15] សំណើទីមួយ កថាខណ្ឌ ១៥-១៨។

ស-២១ គឺមិនអាចទទួលយកបានឡើយ លុះត្រាតែភាគីដែលគិតថាឯកសារនោះពិតបានផ្តល់ភ័ស្តុតាងផ្ទុយពីសច្ចធារណ៍ដែលថា ចម្លើយទាំងនោះបានមកពីការធ្វើទារុណកម្ម[16]។

## ខ. សំណើទីពីរ

12. សំណើទីពីរមានការជាប់ពាក់ព័ន្ធនឹងសាក្សី ម៉ែន ធារី ដែលជាក្មួយស្រីរបស់ រ័ត្ន លាង (ដែលភាសាអង់គ្លេសសរសេរជា Roath Leang, Roat Leang ឬ Rath Leang) ដែលត្រូវបានអះអាងថាជាកម្មាភិបាលដែលត្រូវបានបោសសម្អាត និងការវាយតម្លៃបឋមរបស់អ្នកស៊ើបអង្កេតជាមួយសាក្សីនោះ នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៦ និងការស្តាប់ចម្លើយនៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៦។

13. មេធាវីការពារក្តីបានសង្កត់បញ្ជាក់លើផ្នែកមួយនៃកំណត់ហេតុនៃកិច្ចស៊ើបសួរ ទាក់ទងនឹងការវាយតម្លៃបឋម ដែលជាការសន្ទនានៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងខ្សែអាត់ថតសំឡេងដែលពាក់ព័ន្ធនៃការស្តាប់ចម្លើយ[17] និងលើកឡើងថា៖

ក. ខ្សែអាត់ថតសំឡេងនៃការស្តាប់ចម្លើយហាក់ដូចជាបង្ហាញថា ម៉ែន ធារី បានជឿជាក់ថាអ្នកស៊ើបអង្កេតបានប្រាប់គាត់ក្នុងអំឡុងពេលវាយតម្លៃបឋមថា មាស មុត គឺជាអ្នកទទួលខុសត្រូវចំពោះការស្លាប់របស់ រ័ត្ន លាង ប៉ុន្តែកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីមិនបានបង្ហាញចំណុចនេះទេ[18] និង

ខ. វាទំនងថា អ្នកស៊ើបអង្កេតបានជះឥទ្ធិពលលើការចងចាំដោយឯករាជរបស់សាក្សី ម៉ែន ធារី ដោយនិយាយប្រាប់គាត់ថា មាស មុត កំពុងត្រូវបានស៊ើបអង្កេតពីការបញ្ជូនមនុស្សទៅ

---

[16] សំណើទីមួយ កថាខណ្ឌ ១៩។

[17] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែន ធារី KH ERN 01202829-01202830 ឆ.៣-ឆ.៦, ឆ.១១-ឆ.១២។ ឯកសារ D114/174 ទំព័រ ២។ សំណើទីពីរ កថាខណ្ឌ ៤-៦។

[18] សំណើទីពីរ កថាខណ្ឌ ៦។

មន្ទីរ ស-២១ និងបានបង្ហាញសាក្សីនោះនូវឯកសារមួយដែលចង្អុលបង្ហាញថា រ័ត្ន លាង ត្រូវបានបញ្ជូនទៅ ស-២១[19]។

14. មេធាវីការពារក្តីក៏បានបង្ហាញពីការព្រួយបារម្ភផងដែរថា ម៉ែន ធារី អាចនឹងទទួលរងឥទ្ធិពលពីការផ្តល់យោបល់របស់បុគ្គលម្នាក់ទៀតឈ្មោះ ឡុង ឡាញ ដែលបាននិយាយជាមួយអ្នកស៊ើបអង្កេតផងដែរនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៦ និងបានប្រាប់អ្នកស៊ើបអង្កេតថា គាត់បានឮថា *"មាស មុត បានឲ្យគេចាប់ខ្លួន រ័ត្ន លាង ហើយបញ្ជូនទៅកាន់មន្ទីរ ស-២១"* [20]។

15. ជាទីបញ្ចប់ មេធាវីការពារក្តីបានគូសបញ្ជាក់ពីភាពមិនស៊ីចង្វាក់គ្នាយ៉ាងច្បាស់ក្រឡែតមួយពាក់ព័ន្ធនឹងចម្លើយរបស់សាក្សីនៅក្នុងការវាយតម្លៃបឋម[21]។ ផ្អែកលើឯកសារ D114/174 នៅក្នុងការវាយតម្លៃបឋម ម៉ែន ធារី បានប្រាប់អ្នកស៊ើបអង្កេតថា *"នៅក្នុងពេលម្តងនោះ ម្តាយរបស់គាត់បាននិយាយប្រាប់គាត់ថា មាស មុត ជាអ្នកទទួលខុសត្រូវចំពោះការចាប់ខ្លួន និងការសម្លាប់ឪពុករបស់គាត់"* [22]។ នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាក្សីត្រូវបានថតសំឡេងនៅពេលកំពុងនិយាយថា វាគឺជា*យាយ* របស់គាត់ ដែលបាននិយាយប្រាប់គាត់ពីឪពុករបស់គាត់[23]។

16. អាស្រ័យហេតុនេះ មេធាវីការពារក្តីស្នើសុំឲ្យ ស.ច.ស បំពេញកិច្ចស៊ើបសួរដូចខាងក្រោម ពីព្រោះវានឹងរារាំងមិនឲ្យភ័ស្តុតាងដែលមិនគួរឲ្យជឿជាក់បាន បន្តមាននៅក្នុងសំណុំរឿង និងជួយ ស.ច.ស ក្នុងការវាយតម្លៃបានយ៉ាងត្រឹមត្រូវលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងកំណត់ពីការទទួលខុសត្រូវរបស់ មាស មុត ចំពោះការស្លាប់របស់ រ័ត្ន លាង ដែលត្រូវបានចោទប្រកាន់ [24]៖

---

[19] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៩។

[20] សំណើទីពីរ កថាខណ្ឌ ៤,៨(គ)។ ឯកសារ D114/174 ទំព័រ ៣។

[21] សំណើទីពីរ កថាខណ្ឌ ៥-៦, ៨(ឃ)។

[22] ឯកសារ D114/174 ទំព័រ ៤-៥។

[23] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែន ធារី KH ERN 01202830 ឆ.១១។

[24] សំណើទីពីរ កថាខណ្ឌ ៩-១០។

ក. កំណត់ថាតើអ្នកស៊ើបអង្កេតបំពេញកិច្ចហួសវិសាលភាពនៃកិច្ចសម្ភាសវាយតម្លៃដែលបានអនុញ្ញាតនៅក្នុងពេលជួបជជែកជាមួយនឹងសាក្សី ម៉ែន ធារី កាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៦ ដែរឬយ៉ាងណា។

ខ. កំណត់ថាតើឯកសារពីមន្ទីរ ស-២១ ណាមួយដែលអ្នកស៊ើបអង្កេត បានបង្ហាញដល់សាក្សី ហើយអ្វីឲ្យពិតប្រាកដ ដែលអ្នកស៊ើបអង្កេតបាននិយាយទៅកាន់សាក្សី មុនពេលការអះអាងរបស់គាត់នៅក្នុងការវាយតម្លៃបឋមថា *"ម្ដាយរបស់គាត់បាននិយាយប្រាប់គាត់ថា មាស មុត ជាអ្នកទទួលខុសត្រូវចំពោះការចាប់ខ្លួន និងការសម្លាប់ពូរបស់គាត់"*។

គ. កំណត់ថាតើសាក្សីបានឆ្លើយចម្លើយនេះ នៅមុន ឬនៅក្រោយពេលដែល ឡុង ឡាញ់ បានប្រាប់អ្នកស៊ើបអង្កេតថា គាត់បានឮថា មាស មុត បានឲ្យគេចាប់ខ្លួន រ័ត្ន លាង ហើយបញ្ជូនទៅកាន់មន្ទីរ ស-២១។

ឃ. កំណត់ថាតើមានចម្លើយផ្សេងទៀតដែលបានផ្ដល់ តែមិនត្រូវបានកត់ត្រា ដែលបាននាំឲ្យអ្នកស៊ើបអង្កេត ជឿជាក់ថា *យាយ*របស់សាក្សី និងមិនមែនជា*ម្ដាយ*របស់សាក្សីនោះទេ ដែលបានប្រាប់គាត់ថា មាស មុត បានសម្លាប់ពូរបស់គាត់។

ង. កំណត់ថាតើសាក្សីបានអាន និងយល់ស្របជាមួយនឹងសំណៅចុងក្រោយនៃកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីឬទេ ឬគ្រាន់តែចុះហត្ថលេខាក្រោយពេលគាត់ផ្ដល់យោបល់ ប៉ុន្តែមិនបានពិនិត្យមើលឡើងវិញនូវកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីនោះ ដើម្បីមើលថាតើការកែតម្រូវទាំងនោះត្រូវបានបញ្ចូលទៅក្នុងអត្ថបទចុងក្រោយ ឬយ៉ាងណា និង

ច. ពិនិត្យកែប្រែកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីឡើងវិញ ដើម្បីឆ្លុះបញ្ចាំងការកែតម្រូវកំណត់ហេតុនៃការស្ដាប់ចម្លើយដែលធ្វើឡើងដោយសាក្សី នៅពេលដែលកំណត់ហេតុនេះត្រូវបានអានឲ្យគាត់ស្ដាប់ឡើងវិញ ពោលគឺ អ្នកស៊ើបអង្កេតដែលបានប្រាប់សាក្សីថា មាស មុត បានចាប់ និងសម្លាប់មនុស្សនៅមន្ទីរ ស-២១[25]។

---

[25] សំណើទីពីរ កថាខណ្ឌ ៨។

## III. ការពិភាក្សា

### ក. បទដ្ឋានសម្រាប់ការវាយតម្លៃសំណើបំពេញកិច្ចស៊ើបសួរ

17. អង្គបុរេជំនុំជម្រះ ("អ.ប.ជ") ធ្លាប់បានលើកឡើងថា ភាគីធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរ "*ត្រូវបំពេញលក្ខខណ្ឌរួមគ្នាចំនួនពីរ... ពោលគឺ សំណើត្រូវតែ ៖*

*i. កំណត់បង្ហាញអំពីសកម្មភាពដែលត្រូវធ្វើ ឬដីកាដែលត្រូវធ្វើដោយមានការបញ្ជាក់ឱ្យបានច្បាស់លាស់ ("លក្ខខណ្ឌនៃភាពច្បាស់លាស់") និង*

*ii. បង្ហាញឱ្យបានពិស្តារអំពីមូលហេតុអ្វីបានជាសំណើបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំ .... មានការ "ពាក់ព័ន្ធទៅនឹងការបញ្ជាក់នូវការពិត"* ជាបឋម *("លក្ខខណ្ឌនៃភាពពាក់ព័ន្ធ* ជាបឋម*)*"[26] ។

18. លក្ខខណ្ឌនៃភាពច្បាស់លាស់តម្រូវឱ្យភាគីស្នើសុំ "*ត្រូវមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីធ្វើការបង្ហាញឱ្យបានច្បាស់ដល់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងកិច្ចការអ្វីដែលសហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរ*"[27] ។

19. លក្ខខណ្ឌនៃភាពពាក់ព័ន្ធ *ជាបឋម*មានលក្ខខណ្ឌរងកំណត់ដាច់ពីគ្នាចំនួនពីរ។ លក្ខខណ្ឌរងកំណត់ទីមួយ គឺថាសំណើសុំបំពេញកិច្ចស៊ើបសួរ "*ត្រូវមានការពាក់ព័ន្ធជាមួយនឹងវិសាលភាពនៃការស៊ើបសួរ អនុលោមតាមការកំណត់ និងព្រំដែនដែលបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម*"[28] ។ លក្ខខណ្ឌកំណត់

---

[26] សំណុំរឿង ០០២ ឯកសារ D365/2/17 *សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង* ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០ ("សាលដីកាស្តីពីការពិចារណាឡើងវិញ") កថាខណ្ឌ ៤៧។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ ឯកសារ D320/1/1/4 (កោសលុប) *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១២ របស់ អោ អាន* ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៧ កថាខណ្ឌ ១៣។

[27] សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

[28] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៩។

រងទីពីរ គឺថាសំណើសុំបំពេញកិច្ចស៊ើបសួរ *"ត្រូវរៀបរាប់លម្អិតអំពីមូលហេតុអ្វីបានជាព័ត៌មានដែលបានស្នើសុំនឹងនាំឱ្យរកឃើញការពិត"*[29] ។ លក្ខខណ្ឌរងនេះតម្រូវឱ្យភាគីស្នើសុំបង្កើតចំណងទាក់ទងរវាងសំណើ និងបញ្ហាដែលស្ថិតក្រោមវិសាលភាពនៃកិច្ចស៊ើបសួរជាមួយនឹងសំណើសុំ[30]។

20. ខ្ញុំយល់ថា ទាំងសំណើទីមួយ និងសំណើទីពីរ សុទ្ធតែកំណត់ពីសំណើសុំបំពេញកិច្ចស៊ើបសួរដោយមានភាពច្បាស់លាស់គ្រប់គ្រាន់ ហើយសំណើទាំងនោះសុទ្ធតែបំពេញតាមលក្ខខណ្ឌនៃភាពពាក់ព័ន្ធ*ជាបឋម* ដោយសារតែកិច្ចស៊ើបសួរនោះពាក់ព័ន្ធនឹងភាពអាចជឿជាក់ និងភាពអាចទុកចិត្តបានរបស់ភ័ស្តុតាងដែលមានស្រាប់ក្នុងសំណុំរឿងនេះ។

## ខ. ការប្រើប្រាស់ព័ត៌មានដែលទទួលបានតាមរយៈការធ្វើទារុណកម្ម

### i. ការសង្កេតបឋម

21. ខ្ញុំកត់សម្គាល់ឃើញថា ខណៈដែលសំណើទីមួយមិនទាមទារឱ្យមានការធ្វើមោឃភាពរាល់ភ័ស្តុតាងទាំងឡាយដោយសំអាងថា ភ័ស្តុតាងទាំងនោះជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម សំណើនោះបានគូសបញ្ជាក់ជាមុនអំពីការដាក់ពាក្យស្នើសុំដែលអាចធ្វើឡើង បន្ទាប់ពីមានចម្លើយតបរបស់ខ្ញុំទៅនឹងសំណើទីមួយ[31]។ ដូច្នេះ ដើម្បីលើកឡើងពីក្តីបារម្ភនានាដែលអាចលេចឡើងដោយសារលទ្ធភាពដែលភ័ស្តុតាងមានកំហុសឆ្គងផ្នែកនីតិវិធី ខ្ញុំនឹងផ្តល់ខ្លឹមសារសង្ខេបស្តីពីវិធានដែលគ្របដណ្តប់លើការប្រើប្រាស់ព័ត៌មាន ដែលទទួលបានតាមរយៈការធ្វើទារុណកម្មក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក។

### ii. ការប្រើប្រាស់ឯកសារដែលទទួលបានតាមរយៈការធ្វើទារុណកម្មជាភ័ស្តុតាង

---

[29] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៥០។

[30] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៥០-៥១។

[31] សំណើទីមួយ ទំព័រ ១។

22. នៅ អ.វ.ត.ក អង្គជំនុំជម្រះត្រូវតែទទួលយករាល់ភស្តុតាងទាំងអស់ លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ[32]។ វិធានផ្ទៃក្នុងបញ្ជាក់ពីភស្តុតាង ៥ ប្រភេទដែលអាចបដិសេធចោលបាន ហើយភស្តុតាងមួយក្នុងចំណោមនោះ គឺភស្តុតាងដែល *"ច្បាប់មិនអនុញ្ញាត"*[33] ។ យុត្តិសាស្ត្ររបស់ អ.វ.ត.ក ទទួលស្គាល់ថា *"ច្បាប់ជាធរមាន"* នៅក្នុងប្រទេសកម្ពុជា រាប់បញ្ចូលទាំងលិខិតុបករណ៍អន្តរជាតិមួយចំនួន រួមមាន អនុសញ្ញាប្រឆាំងអំពើទារុណកម្មផងដែរ ("CAT")[34]។

23. មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្ម ដែលកម្ពុជាជារដ្ឋភាគី ចែងថា *"រដ្ឋភាគីត្រូវធានាថា ឯកសារវាយការណ៍ទាំងឡាយណាដែលត្រូវបានកំណត់ថាបានបង្កើតឡើង/បានមកពីអំពើទារុណកម្ម មិនអាចយកមកសំអាងជាភស្តុតាងក្នុងដំណើរការនីតិវិធីណាមួយឡើយ លើកលែងតែការប្រើប្រាស់ឯកសារវាយការណ៍នេះដើម្បីបញ្ជាក់ថា ការវាយការណ៍នេះត្រូវបានធ្វើឡើងដោយការប្រើទារុណកម្មដោយជន ដែលត្រូវចោទថាបានប្រើទារុណកម្ម"* ។ គណៈកម្មាធិការប្រឆាំងអំពើទារុណកម្ម បានគូសបញ្ជាក់ពីលក្ខណៈដាច់ខាតនៃវិធានបដិសេធភស្តុតាងនេះ ដោយលើកឡើងថា៖

> "មាត្រា ១៥ នៃអនុសញ្ញានេះគឺជាលទ្ធផលមួយនៃការហាមឃាត់*ដាច់ខាត*ចំពោះការធ្វើទារុណកម្មដែលជាមូលដ្ឋានរបស់អនុសញ្ញាប្រឆាំងអំពើទារុណកម្មនេះ។ ផ្នែកទីមួយនៃមាត្រានេះត្រូវបានតាក់តែងឡើងដើម្បីលុបបំបាត់អំពើទារុណកម្មគ្រប់ប្រភេទ នៅពេលមានការធ្វើទារុណកម្មលើមនុស្សម្នាក់ក្នុងគោលបំណងទទួលបាន

---

[32] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[33] វិធាន ៨៧(៣)(ឃ) នៃវិធានផ្ទៃក្នុង។

[34] សំណុំរឿង ០០២ ឯកសារ D130/7/3/5 *សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និតរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម* ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៣៥។ សំណុំរឿង ០០២ ឯកសារ D130/10/12 *សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម* ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១០ កថាខណ្ឌ ២៥។

ព័ត៌មាន ឬចម្លើយសារភាពពីជននោះ ឬតតីយជន។ ក្នុងបរិបទនោះ *ឯកសារដែលទទួលបានតាមរយៈការធ្វើទារុណកម្មត្រូវប្រកាសជាមោឃៈជាដាច់ខាត*"[35] (មានការបញ្ជាក់បន្ថែម)។

24. ការហាមឃាត់ដែលមានចែងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្មបានជះឥទ្ធិពលលើបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងកំពុងក្លាយជាគោលការណ៍មូលដ្ឋានដែលត្រូវបានចែងក្នុងយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECtHR")"[36]។

25. មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្មអនុវត្តចំពោះកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក[37]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា តម្លៃជាភ័ស្តុតាងនៃឯកសារដែលទទួលបានតាមរយៈការធ្វើទារុណកម្មត្រូវបានកំណត់ត្រឹមតែអង្គហេតុដែលថា ឯកសារទាំងនោះត្រូវបានបង្កើតឡើង និងក្នុងករណីដែលសមស្រប ធ្វើជាភ័ស្តុតាងបង្ហាញថា ឯកសារទាំងនោះត្រូវបានធ្វើឡើងដោយសារការធ្វើទារុណកម្ម។ ឯកសារទាំងនោះគឺមិនត្រូវបានអនុញ្ញាតឲ្យយកមកប្រើដើម្បីបញ្ជាក់ការពិតនោះទេ[38]។ ការហាមឃាត់នេះមិនឲ្យមានការប្រើប្រាស់ឯកសារដែលទទួលបានតាមរយៈការធ្វើទារុណកម្ម គ្របដណ្តប់លើការប្រើប្រាស់ឯកសារទាំងនោះជាមូលដ្ឋានក្នុងការចោទសួរសាក្សី[39]។ គោលជំហររបស់អង្គជំនុំជម្រះសាលាដំបូងស៊ី

---

[35] គណៈកម្មាធិការប្រឆាំងអំពើទារុណកម្ម *រឿងក្តី PE តទល់នឹងបារាំង* ឯកសារអង្គការសហប្រជាជាតិ CAT/C/29/D/193/2001 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០២ ("រឿងក្តី PE តទល់នឹងបារាំង") កថាខណ្ឌ ៣.២។

[36] តុលាការសិទ្ធិមនុស្សអឺរ៉ុប *រឿងក្តី Jalloh តទល់នឹងអាល្លឺម៉ង់*សាលក្រម, Grand Chamber (ពាក្យសុំលេខ 54810/00) ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ១០៥។ តុលាការសិទ្ធិមនុស្សអឺរ៉ុប *រឿងក្តី Gafgen តទល់នឹង អាល្លឺម៉ង់*សាលក្រម, Grand Chamber (ពាក្យសុំលេខ 22978/05) ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១០ ("សាលក្រម Gafgen") កថាខណ្ឌ ១៦៧។

[37] សំណុំរឿង ០០១ ឯកសារ E1/27.1 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៩ ទំព័រ ៨-៩។

[38] សំណុំរឿង ០០១ ឯកសារ E176 *សេចក្តីសម្រេចលើសំណើរបស់ភាគីនានាសុំដាក់សម្ភារៈមួយចំនួនទៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧ (២)* ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ៨។ សំណុំរឿង ០០២ ឯកសារ E350/8 *សេចក្តីសម្រេចលើភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម* ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ("សេចក្តីសម្រេចលើ

ភ័ស្តុតាង") កថាខណ្ឌ ២០-២១។

[39] សំណុំរឿង ០០២ ឯកសារ E1/129.1 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង* ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ៧៤។ សេចក្តីសម្រេចលើភ័ស្តុតាង កថាខណ្ឌ ២១។

ចង្វាក់គ្នានឹងគោលជំហររបស់អង្គបុរេជំនុំជម្រះដែលកំណត់ថា ការហាមឃាត់ប្រឆាំងនឹងការប្រើប្រាស់ភ័ស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ត្រូវយកមកអនុវត្តយ៉ាងម៉ឺងម៉ាត់[40]។

26. អង្គជំនុំជម្រះតុលាការកំពូល ("អ.ត.ក") បានពិចារណាឃើញដូចគ្នាថា៖

"វិធានបដិសេធភ័ស្តុតាង គ្របដណ្តប់លើការទទួលយកដោយផ្ទាល់នូវព័ត៌មានបានមកពីការធ្វើទារុណកម្ម ធ្វើជាភ័ស្តុតាង ដូចជា ការប្រើប្រាស់នូវការថតចម្លង មិនថាតាមទម្រង់ណានោះទេ រួមទាំងការផលិតឡើងវិញនូវខ្លឹមសារតាមរយៈសាក្សីក៏ដោយ។ បន្ថែមលើនេះ អានុភាពនៃវិធានបដិសេធភ័ស្តុតាងចែងថា ចម្លើយដែលស្ថិតក្រោមវិធាននេះ ពុំអាចត្រូវបានប្រើប្រាស់ក្នុងការបញ្ជាក់ពីការពិតនៃខ្លឹមសារ ឬក៏សូម្បីតែធ្វើសេចក្តីសន្និដ្ឋានដោយប្រយោលថា ខ្លឹមសារនោះអាចជាការពិត ដើម្បីដេញដោលសាក្សីឡើយ"[41]។

27. ឧទាហរណ៍ទូទៅបំផុតនៃភ័ស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្មនៅ អ.វ.ត.ក គឺកំណត់ត្រាឯកសាររបស់អ្នកទោសនៅមន្ទីរ ស-២១ ("ចម្លើយសារភាពបានពីមន្ទីរ ស- ២១")។ អង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូង បានសម្រេចថាមានការផ្អែកទៅលើតែការសន្មតដោយការមិនឯកភាពថា ចម្លើយសារភាពទាំងអស់នៅមន្ទីរ ស-២១ គឺបានមកតាមរយៈការធ្វើទារុណកម្ម និងដូច្នេះមិនអាចទទួលយកជាភ័ស្តុតាងបានឡើយ[42]។ ទោះជាយ៉ាងនេះក្តី មានប្រភេទព័ត៌មានពីរដែលមិនស្ថិតក្នុងប្រភេទនេះ។

---

[40] សំណុំរឿង ០០២ ឯកសារ D130/7/3/5 *សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភ័ស្តុតាង និងការសំអាងទៅលើភ័ស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម* ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១០ (ឯកសារ D130/7/3/5) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ ឯកសារ D130/9/21 *សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម* ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ៣០។

[41] សំណុំរឿង ០០២ ឯកសារ F26/12 *សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ* ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៤៧។ *សូមមើល* កថាខណ្ឌ ៦៦-៦៨។

[42] *សូមមើល* សំណុំរឿង ០០២ ឯកសារ F26/12 *សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ* ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៥៨-៥៩។

28. ទីមួយគឺព័ត៌មានដែលមានក្នុងកំណត់ត្រាអំពីការសួរយកចម្លើយ ប៉ុន្តែជាព័ត៌មានរបស់បុគ្គលផ្សេងទៀត ក្រៅពីជនរងគ្រោះនៃការធ្វើទារុណកម្ម ដូចជា ព័ត៌មាននៃការសួរយកចម្លើយរបស់អ្នកធ្វើទារុណកម្មនៅមន្ទីរ ស-២១ ដែលត្រូវបានកត់ត្រានៅក្នុងចម្លើយសារភាពនៅមន្ទីរ ស-២១។ យោងតាមអង្គជំនុំជម្រះតុលាការកំពូល ព័ត៌មានទាំងនេះអាចប្រើប្រាស់ដើម្បីបញ្ជាក់ពីសំណួរដែលបានសួរអំពីបុគ្គលដែលបានចូលរួម ឬព្រឹត្តិការណ៍ និងជាពិសេសអំពើនៃការធ្វើទារុណកម្មតែម្តង[43]។

29. ទីពីរគឺ "ព័ត៌មានសត្យានុម័ត" ដែលត្រូវបានកត់ត្រានៅមន្ទីរ ស-២១ ដែលអង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូងយល់ថា មិនស្ថិតក្នុងវិធានបដិសេធភ័ស្តុតាងឡើយ[44]។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងថា មិនថាព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម ឬយ៉ាងណានោះទេ គឺជាបញ្ហានៃភ័ស្តុតាង[45]។ មានន័យថា ព័ត៌មានសត្យានុម័តស្ថិតនៅក្រៅការសន្មតជាទូទៅនៃការធ្វើទារុណកម្ម ដែលភ្ជាប់នឹងចម្លើយសារភាពនៅមន្ទីរ ស-២១។ អង្គជំនុំជម្រះសាលាដំបូងយល់ថា ព័ត៌មានសត្យានុម័តអាចរាប់បញ្ចូលព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់អ្នកជាប់ឃុំ ដែលនឹងត្រូវសួរចម្លើយ កាលបរិច្ឆេទចាប់ខ្លួនគាត់ និងកាលបរិច្ឆេទជាប់ឃុំ ឬសម្លាប់[46]។

30. ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងបន្ថែមទៀត និងរួមបញ្ចូលក្នុងចំណោមប្រភេទ "ព័ត៌មានសត្យានុម័ត" នូវចំណុចលម្អិតផ្សេងទៀត ដូចជា មុខរបរពីមុន និង និងតួនាទីរបស់អ្នកទោសក្នុងរបបខ្មែរក្រហម[47]។ សម្រាប់មូលហេតុបន្ទាប់មកទៀត ខ្ញុំយល់

---

[43] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៦៨ សេចក្តីសម្រេចលើភ័ស្តុតាង កថាខណ្ឌ ៤៩។

[44] សំណុំរឿង ០០២ ឯកសារ F26/12 *សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ* ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៦៨។ សេចក្តីសម្រេចលើភ័ស្តុតាង កថាខណ្ឌ ៤៩។

[45] សំណុំរឿង ០០២ ឯកសារ F26/12 *សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ* ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៦៨។

[46] សំណុំរឿង ០០២ ឯកសារ F26/12 *សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ* ថ្ងៃទី ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៦៨។ សេចក្តីសម្រេចលើភ័ស្តុតាង កថាខណ្ឌ ៤៩។

[47] សំណុំរឿង ០០២ ឯកសារ F26/12 *សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ* ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៦៨។

ថា ព័ត៌មានទាំងនេះប្រាកដជាស្ថិតក្នុងការសន្មតថាទទួលបានតាមរយៈការធ្វើទារុណកម្ម និង មិនអាចជឿជាក់បានឡើយ ហើយជាទូទៅអនុវត្តចំពោះចម្លើយសារភាពបានពីមន្ទីរ ស-២១។

31. ប្រភេទព័ត៌មានសត្យានុម័តដែលសំអាងដោយអង្គជំនុំជម្រះ គឺជាព័ត៌មានដែលស្ថិតក្នុង "ជីវប្រវត្តិរបស់អ្នកទោសជាប់ឃុំឃាំង" ដែលជាទូទៅជាឯកសារកម្រាស់មួយទំព័រដែល បង្ហាញពីឈ្មោះរបស់អ្នកជាប់ឃុំឃាំង ឈ្មោះហៅក្រៅ ថ្ងៃខែឆ្នាំកំណើត ភេទ សញ្ជាតិ តួនាទី និងអង្គភាពក្នុង *"បដិវត្តន៍"* ទីកន្លែងកំណើត ឈ្មោះ និងមុខរបររបស់ឪពុកម្តាយ ឈ្មោះរបស់ ប្តី/ប្រពន្ធ និងទីកន្លែងកំណើត ចំនួនកូន និងកាលបរិច្ឆេទ និងទីកន្លែងឃាត់ខ្លួន[48]។ ក្នុង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៣ ឌុច បានពន្យល់ថា *"ការធ្វើប្រវត្តិ រូបមិនធ្វើទារុណកម្មទេ"*[49]។ ប៉ុន្តែនៅពេលសួរសំណួរតាមដានបន្តថា *"តើយើងយល់ត្រឹមត្រូវ ដែរ ឬទេ ថាលោកអះអាងថា* ***ជាទូទៅ*** *គឺពុំប្រើការធ្វើទារុណកម្មទេ ពេលធ្វើប្រវត្តិរូប លើក លែងតែមានការបំពានដោយអ្នកសួរខ្លួនឯង តែវាពុំស្របទៅនឹងគោលការណ៍នោះទេ?* (មាន ការបញ្ជាក់បន្ថែម) គាត់បានឆ្លើយថា *"បាទ ត្រឹមត្រូវ"*[50] និងមិនជំទាស់នឹងលក្ខខណ្ឌ *"ជា ទូទៅ"* ក្នុងសំណួរនេះឡើយ។ លើសពីនេះ មានការគំរាមធ្វើទារុណកម្ម[51] ហើយថាតើមានការ គំរាមកំហែង ឬការភ័យខ្លាចការទទួលទារុណកម្មក្នុងពេលធ្វើជីវប្រវត្តិ ឬយ៉ាងណានោះ *"គឺវា ស្រេចនឹងការប៉ិនប្រសប់របស់អ្នកសួរ"*[52]។ ការស្រង់ជីវប្រវត្តិ និងចម្លើយសារភាពត្រូវបានធ្វើ ឡើងក្នុងបន្ទប់តែមួយ និងដោយអ្នកសួរចម្លើយដដែល[53]។ គេមិនដឹងច្បាស់ថាតើអ្នកជាប់ឃុំ ឃាំងបានឃើញភ័ស្តុតាងនៃការធ្វើទារុណកម្ម នៅពេលធ្វើជីវប្រវត្តិ របស់ពួកគេ ឬយ៉ាងណា នោះទេ[54] ប៉ុន្តែយោងតាមចម្លើយរបស់ ឌុច *"អ្នកខ្លះក៏យល់ឃើញថា ខ្លួនគេចមិនផុតពីទទួល*

---

[48] *សូមមើល ឧ.* សំណុំរឿង ០០៣ ឯកសារ D59/1/3.51b *ប្រវត្តិរូបរបស់ ហួន យ៉េង*។

[49] សំណុំរឿង ០០៣ ឯកសារ D114/158 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច* ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៦ KH ERN 01202333 ឆ. ១៤។

[50] *ដូចជើងទំព័រខាងលើ* KH ERN 01202334 ឆ. ១៦។

[51] *ដូចជើងទំព័រខាងលើ* KH ERN 01202336 ឆ. ១៩។

[52] *ដូចជើងទំព័រខាងលើ* KH ERN 01202334 ឆ. ១៧។

[53] *ដូចជើងទំព័រខាងលើ* KH ERN 01202338-01202339 ឆ. ២៥, ឆ. ២៨។

[54] *ដូចជើងទំព័រខាងលើ* KH ERN 01202339 ឆ. ២៩។

*ទារុណកម្មទេ”*[55] ។ ដូច្នេះ វាមិនទំនងទាល់តែសោះដែលថា អ្នកជាប់ឃុំមួយចំនួននៅមន្ទីរ ស-២១ បានផ្តល់ព័ត៌មានប្រវត្តិរូបដោយសារការធ្វើទារុណកម្ម ការបង្ខិតបង្ខំ ឬការភ័យខ្លាចការទទួលទារុណកម្ម។

32. ព័ត៌មានលម្អិត ដូចជា ភេទរបស់អ្នកដែលត្រូវបានចាប់ខ្លួន និងកាលបរិច្ឆេទ និងទីកន្លែងនៃការចាប់ខ្លួនអាចចាត់ទុកថាមានលក្ខណៈ*សត្យានុម័ត* ព្រោះវាជាទិន្នន័យដែលអ្នកចាប់ខ្លួនបានដឹងដោយមិនគិតពីការលើកឡើងរបស់អ្នកជាប់ឃុំឃាំង។

33. ទោះយ៉ាងនេះក្តី អ្នកចាប់ឃាត់ខ្លួនអាចមិនបានដឹងពីព័ត៌មាននានា ដូចជា មុខរបរពីមុនរបស់អ្នកទោស មុខរបរឪពុកម្តាយរបស់អ្នកទោស និងឈ្មោះសាច់ញាតិរបស់អ្នកទោស។ សូម្បីតែតួនាទីរបស់អ្នកទោសតាំងពីពេលចាប់ផ្តើមបដិវត្តន៍ក៏អ្នកសួរចម្លើយ មិនអាចដឹងបានពេញលេញ ឬត្រឹមត្រូវដែរ។ នៅពេលពិចារណាពីនីតិវិធីក្នុងការធ្វើប្រវត្តិរូបដែលពន្យល់រៀបរាប់ដោយ ឌុច និងអង្គហេតុដែលបង្ហាញថា ព័ត៌មានប្រភេទនេះពាក់ព័ន្ធនឹងការវាយតម្លៃរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះ “សមាសភាពមិនល្អ” ដែលរងការចោទប្រកាន់ អ្នកទោសអាចនឹងបាននិយាយកុហកនៅពេលផ្តល់ព័ត៌មានស្តីពីសាវតាររបស់ខ្លួន។

34. ចុងក្រោយ ខ្ញុំយល់ថា ឈ្មោះរបស់អ្នកជាប់ឃុំដែលត្រូវបានកត់ត្រាក្នុងជីវប្រវត្តិ ឬក្នុងចម្លើយសារភាព ក៏មិនស្ថិតក្រោមវិសាលភាពនៃវិធានបដិសេធភ័ស្តុតាងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្មដែរ។ វាមិនមែនជាព័ត៌មានសត្យានុម័ត ដូចជា ភេទរបស់អ្នកជាប់ឃុំ និងកាលបរិច្ឆេទនៃការចាប់ខ្លួន ឬសម្លាប់នោះទេ។ ប៉ុន្តែមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្ម អនុញ្ញាតឲ្យមានការប្រើប្រាស់ចម្លើយដែលទទួលបានតាមរយៈការធ្វើទារុណកម្មប្រឆាំងជនដែលជាប់ចោទថាបានធ្វើទារុណកម្ម *“ជាភ័ស្តុតាងដែលទទួលបានពីចម្លើយនោះ”* ។ ដើម្បីបញ្ជាក់ថា ចម្លើយនោះទទួលបានតាមរយៈការធ្វើទារុណកម្ម និងដើម្បីផ្តន្ទាទោសអ្នកធ្វើទារុណកម្ម ឈ្មោះរបស់ជនរងគ្រោះគឺជាព័ត៌មានដ៏សំខាន់មួយ។ គេអាចវាយតម្លៃភាពអាចជឿជាក់បានរបស់ព័ត៌មាននោះតាមរយៈការពន្យល់បកស្រាយតាមន័យធម្មតា។

---

[55] *ដូចជើងទំព័រខាងលើ* KH ERN 01202340 ឆ. ៣០។

35. ដូច្នេះ ខ្ញុំយល់ឃើញថា ព័ត៌មានដែលមានក្នុងជីវប្រវត្តិ ក្រៅពី ក) ឈ្មោះរបស់អ្នកទោស ខ) ភេទរបស់អ្នកទោស និង គ) កាលបរិច្ឆេទចាប់ខ្លួន ឬសម្លាប់អ្នកទោស ត្រូវមានតម្លៃដូចគ្នានឹងព័ត៌មានដែលមានក្នុងចម្លើយសារភាពសមស្រប និងដូច្នេះ មិនត្រូវប្រើប្រាស់ជាភ័ស្តុតាង ឬសំអាងលើសាក្សីក្នុងពេលចោទសួរឡើយ។ ទោះយ៉ាងនេះក្តី វាជារឿងសមហេតុផលដែលការប្រើប្រាស់ព័ត៌មានទាំងនោះ ទោះបីជាជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មក្តី មានផលប៉ះពាល់តិចតួចលើគុណភាពនៃការលើកឡើងរបស់សាក្សី ប្រសិនបើត្រូវបានប្រើប្រាស់ក្នុងការស្តាប់ចម្លើយ និងមិនមែនជាសមាសធាតុនៃផ្នែកសំខាន់ដែលត្រូវការពារដោយគោលបំណងគោលនយោបាយដែលមានចែងខាងលើឡើយ។

iii. <u>ការប្រើប្រាស់ព័ត៌មានដោយពឹងផ្អែកលើចម្លើយដែលទទួលបានតាមរយៈការធ្វើទារុណកម្មជាតម្រុយស៊ើបអង្កេត</u>

36. ការហាមឃាត់ដាច់ខាតទៅលើការប្រើប្រាស់ចម្លើយ ដែលទទួលបានតាមរយៈការធ្វើទារុណកម្មជាភ័ស្តុតាង មិនបានរារាំងសហចៅក្រមស៊ើបអង្កេត ដោយផ្អែកលើលក្ខខណ្ឌដែលបានបញ្ជាក់បន្ថែមទៀតនៅក្នុងផ្នែកនេះ មិនឲ្យប្រើប្រាស់ខ្លឹមសារនៃចម្លើយសារភាពពីមន្ទីរ ស-២១ ជាតម្រុយស៊ើបអង្កេតនោះទេ។ មានមូលហេតុចំនួនពីរដែលគាំទ្រដល់សេចក្តីសន្និដ្ឋាននេះ ។

37. ទីមួយ ការហាមឃាត់ដែលមានចែងនៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្ម និងដែលបានប្រើប្រាស់ដោយអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា និងស្ថាប័នសិទ្ធិមនុស្សនានា ទាក់ទងតែនឹងការប្រើប្រាស់ព័ត៌មានដែលទទួលបានតាមរយៈការធ្វើទារុណកម្មជា *ភ័ស្តុតាង* ប៉ុណ្ណោះ[56]។

38. ទីពីរ ការប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពពីមន្ទីរ ស-២១ ជាតម្រុយនោះ មិនបានផ្ទុយទៅនឹងហេតុផលគោលនយោបាយណាមួយ ដែលកំណត់ដោយវិធានបដិសេធភ័ស្តុតាងនោះឡើយ ពោលគឺ (i) ការរារាំងដល់ការសំអាងលើភ័ស្តុតាងដែលមិនគួរទុកចិត្តសោះ

---

[56] *សូមមើលខាងលើ* ផ្នែកIII(ខ)(ii)។

(ii) ការដកចេញនូវហេតុផលរបស់អាជ្ញាធរក្នុងការចូលរួមធ្វើទារុណកម្ម និង (iii) ការរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីតុលាការ[57]។

39. ទាក់ទងទៅនឹងហេតុផលគោលនយោបាយ (i) ភាពមិនអាចជឿជាក់បាននៃចម្លើយសារភាពពីមន្ទីរ ស-២១ ដែលនាំទៅដល់តម្រុយស៊ើបអង្កេត មិនប៉ះពាល់ដល់ភាពអាចជឿជាក់បាននៃភ័ស្តុតាងរបស់សាក្សីដែលបានរកឃើញតាមរយៈតម្រុយនោះទេ។ ចម្លើយសារភាពពីមន្ទីរ ស-២១ ដែលមិនត្រឹមត្រូវ ជាធម្មតាគ្មានភាពពាក់ព័ន្ធដល់ភាពអាចជឿជាក់បាននៃចម្លើយថ្មីទេ លុះត្រាតែខ្លឹមសារនៃចម្លើយសារភាពពីមន្ទីរ ស-២១ ត្រូវបានប្រគល់ទៅឱ្យសាក្សីដែលមាននៅក្នុងតម្រុយនេះ។

40. នៅក្នុងករណីខ្លះ (ii) ការប្រើប្រាស់ព័ត៌មានដែលទទួលបានតាមរយៈការធ្វើទារុណកម្មជាតម្រុយ អាចប៉ះពាល់ដល់ហេតុផលគោលនយោបាយ ។ ជាឧទាហរណ៍ ករណីនេះកើតមានប្រសិនបើព័ត៌មានដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ត្រូវបានប្រើប្រាស់ដោយអាជ្ញាធរធ្វើទារុណកម្មដើម្បីកំណត់រកសាក្សី ឬឯកសារ ដើម្បីប្រើប្រាស់ជាភ័ស្តុតាង នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ។ ក្នុងសេណារីយ៉ូនេះ ការអនុញ្ញាតឱ្យប្រើប្រាស់ភ័ស្តុតាងដែលកំណត់បានតាមរយៈការធ្វើទារុណកម្ម អាចជំរុញឱ្យអាជ្ញាធរងាកទៅប្រើប្រាស់ការធ្វើទារុណកម្មជាឧបករណ៍នៃការស៊ើបអង្កេត។

41. ទោះជាយ៉ាងណាក៏ដោយ ក៏ការប្រើប្រាស់ព័ត៌មានរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបានរកឃើញនៅក្នុងចម្លើយសារភាពពីមន្ទីរ ស-២១ ឬជីវប្រវត្តិ ជាតម្រុយនេះ មិនដូចគ្នាទៅនឹងសេណារីយ៉ូដែលបានរៀបរាប់ខាងលើទេ។ តាមការស្រាវជ្រាវរបស់ខ្លួន ការិយាល័យសហចៅក្រមស៊ើបអង្កេតមានឯកសារពីបណ្ណសារ ជាពិសេស ជាទម្រង់នៃចម្លើយសារភាពពីមន្ទីរ ស-២១ ដែលទំនងជាទទួលបានតាមរយៈការធ្វើទារុណកម្ម ដោយអាជ្ញាធររបស់រដ្ឋដែលអតីតមន្ត្រីដែលបានរងការចោទប្រកាន់ កំពុងត្រូវបានស៊ើបអង្កេតដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។ ការិយាល័យសហចៅក្រមស៊ើបអង្កេតពុំមានទំនាក់

---

[57] Michael P. Scharf, "ប្រភពមិនច្បាស់លាស់៖ បើសិនជាមាន តើនៅពេលណាការទើបភ័ស្តុតាងទារុណកម្មអាចទទួលយកបាន?" (១៩៩៨) *ទីក្រុងវ៉ាស៊ីនតោន ៦៥ និងការត្រួតពិនិត្យច្បាប់លី ១២៩* ទំព័រ ១៧១។

ទងដោយផ្ទាល់ ឬដោយប្រយោលជាមួយអាជ្ញាធរធ្វើទារុណកម្មនេះទេ ហើយនឹងប្រើប្រាស់តម្រុយដែលអាចមានដើម្បីកំណត់រកភ័ស្តុតាងពាក់ព័ន្ធដល់ការស៊ើបអង្កេតទៅក្នុងការប្រព្រឹត្តិរបស់ជន ដែលជាអតីតមន្ត្រី ដែលត្រូវបានចោទប្រកាន់ថាជាអាជ្ញាធរធ្វើទារុណកម្មនេះ។ នៅក្នុងសេណារីយ៉ូបែបនេះ ការអនុញ្ញាតឱ្យប្រើប្រាស់ភ័ស្តុតាងដែលបានរកឃើញនៅ មន្ទីរ ស-២១ មិនបានជំរុញដល់ការប្រើប្រាស់ការធ្វើទារុណកម្ម (តាមពិតទៅ វាអាចផ្តល់នូវឥទ្ធិពលផ្ទុយគ្នាទៅវិញទេ ពោលគឺបង្អាក់ទឹកចិត្តដល់ការធ្វើទារុណកម្ម តាមរយៈការទប់ស្កាត់ពិសេសប្រសិនបើមានការផ្តន្ទាទោសត្រូវបានធានាតាមរយៈភ័ស្តុតាងនេះ)។

42. ជាចុងក្រោយ (iii) ទាក់ទងទៅនឹងហេតុផលគោលនយោបាយ ក្នុងករណីគ្មានការហាមឃាត់ ឬហានិភ័យដែលប៉ះពាល់ដល់គោលបំណងនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងអំពើ ទារុណកម្ម នោះ ការប្រើប្រាស់ចម្លើយសារភាពពីមន្ទីរ ស-២១ ឬជីវប្រវត្តិ ជាតម្រុយ មិនបានធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធីទេ។

43. ក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា វិធានបដិសេធភ័ស្តុតាង ដែលមានចែងក្នុងមាត្រា ១៥ មិនត្រូវបានអនុវត្តចំពោះ “ភ័ស្តុតាងដែលមិនពេញលក្ខណៈផ្លូវច្បាប់” *(“ភ័ស្តុតាងដែលមិនមែនបានមកដោយអំពើទារុណកម្មដោយផ្ទាល់ ប៉ុន្តែជាភ័ស្តុតាងដែលទទួលបានរកតាមរយៈការធ្វើទារុណកម្ម”)*[58]។ អង្គជំនុំជម្រះសាលាដំបូងពុំអាចរកឃើញភ័ស្តុតាងនៃការបង្ហាញបទដ្ឋានអន្តរជាតិ ទាក់ទងនឹងការប្រើប្រាស់នៃការធ្វើទារុណកម្មខុសច្បាប់នេះទេ[59] ហើយបានសម្រេចថា ទាំងការងារត្រៀមរៀបចំអនុសញ្ញាប្រឆាំងអំពើទារុណកម្ម ទាំងយុត្តាធិការអន្តរជាតិដែលមានលក្ខណៈស៊ីចង្វាក់គ្នា មិនបានគាំទ្រដល់ការពង្រីកវិធានបដិសេធភ័ស្តុតាងដើម្បីបញ្ចូលភ័ស្តុតាងខុសច្បាប់នោះទេ។ ដូច្នេះ អង្គជំនុំជម្រះសន្និដ្ឋានថា *“ភាពអាចទទួលយកបានដោយសេរីនៃភ័ស្តុតាង ដែលគាំទ្រដល់ការទទួលយកបាននូវភ័ស្តុតាងខុសច្បាប់ដរាបណាការប្រើប្រាស់ដែលបានស្នើឡើង មិនបានចៀសវាងការហាមឃាត់ប្រឆាំងនឹងការយកខ្លឹមសារនៃចម្លើយសារភាពដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ដើម្បីបង្ហាញការ*

---

[58] សេចក្តីសម្រេចលើភ័ស្តុតាង កថាខណ្ឌ ៦៣, ៧០។

[59] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ៦៩។

*ពិតនៃភ័ស្តុតាងនោះ"*។ តាមពិត អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា តម្លៃនៃភ័ស្តុតាងតាងបែបនេះ នឹងត្រូវបានវាយតម្លៃទៅតាមករណីជាក់ស្តែង[60]។

44. ដូច្នេះ គ្មានការហាមឃាត់នោះទេនៅ អ.វ.ត.ក ក្នុងការបន្តស្វែងរកតម្រុយស៊ើបអង្កេតដែលមាននៅក្នុងចម្លើយសារភាពពីមន្ទីរ ស-២១ និងក្នុងការសំអាងលើភ័ស្តុតាងដែលអាចត្រូវបានរកឃើញតាមរយៈតម្រុយបែបនោះ។ ការសន្និដ្ឋានផ្ទុយពីនេះនឹងរារាំងដល់កាត់ទោសលើការធ្វើទារុណកម្មថាជាបទឧក្រិដ្ឋ ហើយប្រឆាំងជាសារវន្តទៅនឹងផលប្រយោជន៍យុត្តិធម៌។ ជាក់ស្តែង នៅពេលសាក្សីត្រូវបានកំណត់អត្តសញ្ញាណបានតាមរបៀបនេះ អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវតែចៀសវាងដាក់ព័ត៌មានរបស់សាក្សីដែលមាននៅក្នុងចម្លើយសារភាពពីមន្ទីរ ស-២១ ឬក្នុងជីវប្រវត្តិ (ក្រៅអំពីឈ្មោះរបស់អ្នកនិពន្ធចម្លើយសារភាព ភេទ និងកាលបរិច្ឆេទនៃការចាប់ខ្លួន និង/ឬការប្រហារជីវិតរបស់គាត់ ឬនាង ដែលដូចដែលខ្ញុំបានបញ្ជាក់ខាងលើ ស្ថិតក្នុងការប្រើប្រាស់ចម្លើយសារភាពបានមក តាមរយៈការធ្វើទារុណកម្មដែលគេអាចអនុញ្ញាត ដោយអនុលោមតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្ម ឬដែលជាព័ត៌មានសត្យានុម័ត)។

### គ. សំណើទីមួយ

45. អ្នកស៊ើបអង្កេត Stephen Tedder លែងជាអ្នកស៊ើបអង្កេតដែលធ្វើការនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតទៀតហើយ។ ដូច្នេះ ចម្លើយតបរបស់ខ្ញុំចំពោះសំណួរដែលលើកឡើងដោយក្រុមមេធាវីការពារក្តី គឺផ្អែកតែទៅលើការពិនិត្យឡើងវិញរបស់ខ្ញុំលើឯកសារដែលដាក់ស្នើដោយអ្នកស៊ើបអង្កេតលើសំណុំរឿងនេះ បន្ទាប់ពីបេសកកម្មរបស់គាត់ និងការពិគ្រោះយោបល់របស់ខ្ញុំជាមួយនឹងបុគ្គលិក និងអ្នកវិភាគរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលចូលរួមក្នុងកិច្ចស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ នេះប៉ុណ្ណោះ។

iv. <u>ម៉ែន ធារី</u>

---

[60] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៧០។

46. ដូចដែលបានបង្ហាញនៅក្នុងឯកសារ D114/174 ដែលរាយការណ៍ស្តីពីបេសកកម្មស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបានកើតឡើងពីថ្ងៃទី ២៨ ខែ មករា ដល់ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ អ្នកស៊ើបអង្កេត *"បានធ្វើសេចក្តីសម្រេចផ្អែកប្រតិបត្តិការរបស់ខ្លួន ... ព្យាយាមស្វែងរកសមាជិកគ្រួសារជិតបំផុត ដែលត្រូវបានបញ្ជាក់នៅក្នុងជីវប្រវត្តិពីមន្ទីរ ស-២១ របស់កម្មាភិបាលដែលត្រូវបានចោទសម្លាត (ប្រហែលជាដូច្នេះ) នៅខេត្តក្រចេះពីខែ វិច្ឆិកា/ធ្នូ ឆ្នាំ ១៩៧៨"*[61]។ ក្នុងអំឡុងបេសកកម្មនេះ អ្នកស៊ើបអង្កេតបានសំអាងលើជីវប្រវត្តិពីមន្ទីរ ស-២១ របស់ រ័ត្ន លាង ដែលត្រូវបានចម្លងចេញពីសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេស ដោយអ្នកវិភាគរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតម្នាក់។ ច្បាប់ថតចម្លងនៃជីវប្រវត្តិពីមន្ទីរ ស-២១ និងការបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសនៃជីវប្រវត្តិនោះនឹងត្រូវដាក់បញ្ចូលក្នុងសំណុំរឿងដូចមានចែងក្នុងឧបសម្ពន្ធនៃសេចក្តីសម្រេចនេះ។

47. ជីវប្រវត្តិពីមន្ទីរ ស-២១ កត់ត្រាពីទីកន្លែងកំណើតរបស់ រ័ត្ន លាង នៅភូមិត្រពាំងគល់ ឃុំពពេល ស្រុកត្រាំកក់។ ដោយផ្អែកលើព័ត៌មាននោះ អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើដំណើរទៅកាន់ភូមិនោះ ដែលនៅទីនោះពួកគេបានជួបនឹង ម៉ែន ធារី ដែលបានបញ្ជាក់អត្តសញ្ញាណខ្លួនឯងថាជាក្មួយស្រីរបស់ រ័ត្ន លាង[62]។

48. វាទំនងជាថា អ្នកស៊ើបអង្កេតបានបង្ហាញជីវប្រវត្តិបានពីមន្ទីរ ស-២១ របស់ រ័ត្ន លាង ដល់ ម៉ែន ធារី ក្នុងអំឡុងពេលវាយតម្លៃបឋម[63]។ ទោះយ៉ាងណា បន្ទាប់ពីការពិនិត្យឡើងវិញលើកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកនៃការថតសំឡេងនៃការស្តាប់ចម្លើយ (ដែលបានភ្ជាប់ជាមួយសេចក្តីសម្រេចនេះ) វាច្បាស់ណាស់ថា គ្មានចំណុចណាមួយក្នុងការស្តាប់ចម្លើយដែល

---

[61] ឯកសារ D114/174 ទំព័រ ៣។

[62] *ដូចជើងទំព័រខាងលើ*។

[63] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែន ធារី KH ERN 01202829, ឆ. ២: *"ម្សិលវិញ យើងក៏បានបង្ហាញឯកសារដែលយើងបានមកពីទួលស្លែងពីការចាប់ពូរបស់អ្នក។ តើត្រូវទេ?"*។ សំណុំរឿង ០០៣ ឯកសារ D251.2 *ប្រតិចារឹកនៃការស្តាប់ចម្លើយ ម៉ែន ធារី* ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៦ ("ប្រតិចារឹក ម៉ែន ធារី") ទំព័រ ១១៖ អ្នកបកប្រែ [ភាសាខ្មែរ]៖ *"ម្សិលវិញ យើងបានបង្ហាញឯកសារដែលលោកពូ រត្ន័ លាង ត្រូវបានគេចាប់ខ្លួននៅទួលស្លែង។ ត្រូវទេ?"* ម៉ែន ធារី [ភាសាខ្មែរ]: *"ចាស"*។

អ្នកស៊ើបអង្កេតសំដៅដល់ខ្លឹមសារនៃជីវប្រវត្តិ ឬចម្លើយសារភាពពីមន្ទីរ ស-២១ និងសាកសួរសាក្សីដោយផ្អែកលើព័ត៌មាននោះឡើយ។ ដូច្នេះ ខ្ញុំយល់ឃើញថា គ្មានការធ្វើឱ្យប៉ះពាល់ដល់ភ័ស្តុតាងរបស់ ម៉ែន ធារី ឡើយ។

v. ឈុំ យ៉ា

49. ក្នុងបេសកកម្មដូចគ្នាដែលបានកត់ត្រាក្នុងឯកសារ D114/174 អ្នកស៊ើបអង្កេតបានសំអាងលើជីវប្រវត្តិរបស់ ឈុំ ចិន ពីមន្ទីរ ស-២១ ដែលត្រូវបានថតចម្លងពីសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសដោយអ្នកវិភាគម្នាក់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ច្បាប់ថតចម្លងនៃជីវប្រវត្តិពីមន្ទីរ ស-២១ និងការបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសនៃជីវប្រវត្តិនេះ នឹងត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងដូចមានក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។ ជីវប្រវត្តិពីមន្ទីរ ស-២១ គ្មានការចុះកាលបរិច្ឆេទទេ និងរាយនូវទិន្នន័យជីវប្រវត្តិរបស់ ឈុំ ចិន នោះទេ។

50. ជីវប្រវត្តិពីមន្ទីរ ស-២១ កត់ត្រាពីទីកន្លែងកំណើតរបស់ ឈុំ ចិន នៅភូមិក្បាលអូរ ឃុំជាងទង ស្រុកត្រាំកក់។ ដោយផ្អែកលើព័ត៌មាននេះ អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើដំណើរទៅកាន់ភូមិក្បែរខាងនោះ គឺភូមិស្រែគ្រូ នៅក្នុងឃុំជាមួយគ្នា ដែលនៅទីនោះ ពួកគេបានជួបជាមួយ ឈុំ យ៉ា ដែលបានកំណត់អត្តសញ្ញាណខ្លួនឯងថាជាប្អូនស្រីរបស់ ឈុំ ចិន[64]។

51. គ្មានការចង្អុលបង្ហាញណាមួយឡើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ ឈុំ យ៉ា ដែលថាអ្នកស៊ើបអង្កេតបានបង្ហាញដល់គាត់នូវជីវប្រវត្តិពីមន្ទីរ ស-២១ របស់ ឈុំ ចិន ឬថា ព័ត៌មានដែលមានជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មណាមួយត្រូវបានបង្ហើបប្រាប់ដល់សាក្សីនោះ។

vi. ព្រំ ម៉ុន

52. ក្នុងឯកសារ D114/184 ដែលរាយការណ៍ស្តីពីបេសកកម្មស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបានធ្វើឡើងពីថ្ងៃទី ១៤ ដល់ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ អ្នក

[64] ឯកសារ D114/174 កថាខណ្ឌ ៤។

ស៊ើបអង្កេតបានលើកឡើងពី *"ការប៉ុនប៉ងកំណត់ទីតាំងរបស់សមាជិកគ្រួសារសាច់ញាតជិតដែលបានរៀបរាប់នៅក្នុងជីវប្រវត្តិពីមន្ទីរ ស-២១ របស់កម្មាភិបាលដែលត្រូវបានបោសសម្អាត នៅខេត្តក្រចេះពីខែ វិច្ឆិកា/ធ្នូ ឆ្នាំ ១៩៧៨"*[65]។ នៅក្នុងបេសកកម្មនេះ អ្នកស៊ើបអង្កេតបានពឹងផ្អែកលើជីវប្រវត្តិពីមន្ទីរ ស-២១ របស់ ឃុន សារ៉ុម ដែលបានថតចម្លងចេញពីសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសដោយអ្នកវិភាគម្នាក់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ច្បាប់ថតចម្លងនៃជីវប្រវត្តិពីមន្ទីរ ស-២១ និងការបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសនៃជីវប្រវត្តិនោះ នឹងត្រូវដាក់បញ្ចូលក្នុងសំណុំរឿងដូចមានក្នុងឧបសម្ពន្ធនៃសេចក្តីសម្រេចនេះ។

53. ជីវប្រវត្តិពីមន្ទីរ ស-២១ បានកត់ត្រាឈ្មោះ ព្រំ ម៉ុន ជាភរិយារបស់ ឃុន សារ៉ុម និងចុះទីកន្លែងកំណើតរបស់គាត់ នៅភូមិអន្លង់កញ្ចុះ ឃុំប្រឡាយមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ ដោយផ្អែកលើព័ត៌មាននេះ អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើដំណើរទៅកាន់ភូមិនោះ ជាទីដែលពួកគេបានជួបជាមួយប្រធានភូមិដែលនាំពួកគេទៅផ្ទះរបស់ ព្រំ ម៉ុន ភ្លាមៗ[66]។

54. នៅក្នុងការស្តាប់ចម្លើយនេះ អ្នកស៊ើបអង្កេតបានយោងដល់ជីវប្រវត្តិពីមន្ទីរ ស-២១ នៅពេលព្យាយាមបញ្ជាក់កាលកំណត់របស់សាក្សី ទាក់ទងនឹងការចាប់ខ្លួនប្តីរបស់គាត់ដូចខាងក្រោម៖

| | |
|---|---|
| សំណួរ៖ | *"ដោយផ្អែកលើជីវប្រវត្តិពីទួលស្លែង ប្តីរបស់អ្នកស្រីត្រូវបានចាប់ខ្លួននៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ១៩៧៨។ អ្នកស្រីចាំបានទេថាតើព្រឹត្តិការណ៍នោះត្រូវគ្នានឹងអាយុរបស់កូនអ្នកស្រីឬទេ?"* |
| ចម្លើយទី៤៥៖ | *"ទេ ខ្ញុំមិនចាំទេ"* [67]។ |

55. ដូចដែលខ្ញុំបានពន្យល់ខាងលើ ខ្ញុំចាត់ទុកកាលបរិច្ឆេទនៃការចាប់ខ្លួននោះថាជាព័ត៌មានសត្យានុម័ត ហើយដូច្នេះមិនត្រូវបានគ្របដណ្តប់ដោយវិធានបដិសេធភ័ស្តុតាងនោះទេ។ គ្មាន

---

[65] ឯកសារ D114/184 កថាខណ្ឌ ២។

[66] *ដូចជើងទំព័រខាងលើ*។

[67] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន KH ERN 01204170 ឆ. ៤៥។

ការចង្អុលបង្ហាញណាមួយ ទាំងក្នុងកំណត់ហេតុស្តាប់ចម្លើយក្តី ឬការថតសំឡេងឯងក្តី[68] នៃការសួរចម្លើយក្តីរបស់ ព្រំ ម៉ុន ថា ចៅក្រមស៊ើបអង្កេតបានចែករំលែកព័ត៌មានដែលមានជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មណាមួយជាមួយនឹងសាក្សីឡើយ។

vii. <u>កែវ សារួន</u>

56. ក្នុងបេសកកម្មដូចគ្នាដែលបានកត់ត្រាក្នុងឯកសារ D114/184 អ្នកស៊ើបអង្កេតបានសំអាងលើជីវប្រវត្តិពីមន្ទីរ ស-២១ របស់ ហួន យ៉េង ដែលបានថតចម្លងចេញពីសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសដោយអ្នកវិភាគម្នាក់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ជីវប្រវត្តិពីមន្ទីរ ស-២១ របស់ ហួន យ៉េង មាននៅក្នុងសំណុំរឿងរួចទៅហើយ[69]។ ច្បាប់ថតចម្លងនៃការបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសនឹងត្រូវដាក់បញ្ចូលក្នុងសំណុំរឿង ដូចមានក្នុងឧបសម្ពន្ធនៃសេចក្តីសម្រេចនេះ។

57. ជីវប្រវត្តិនោះបានកត់ត្រាឈ្មោះ "កែវ រួន" ជាភរិយារបស់ ហួន យ៉េង និងចុះទីកន្លែងកំណើតរបស់គាត់ នៅភូមិនាងមាស ឃុំមានជ័យ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ បន្ទាប់ពីស្វែងរកឃុំជ្រៃបាក់ យ៉ាងល្អិតល្អន់ អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើដំណើរទៅកាន់ភូមិមួយផ្សេងទៀត គឺភូមិ អូរកំណប់ ក្នុងខេត្តកំពង់ឆ្នាំង ជាទីដែលពួកគេបានជួបជាមួយ កែវ សារួន ដែលបានកំណត់អត្តសញ្ញាណខ្លួនឯងថាជាភរិយារបស់ ហួន យ៉េង និងបានបញ្ជាក់ឈ្មោះហៅក្រៅរបស់គាត់ថា "កែវ រួន"[70]។

58. នៅក្នុងការស្តាប់ចម្លើយនោះ អ្នកស៊ើបអង្កេតបានយោងដល់ជីវប្រវត្តិពីមន្ទីរ ស-២១ នៅពេលសាកសួរសាក្សីអំពីមុខតំណែងប្តីរបស់គាត់ក្នុងគណៈកម្មាធិការតំបន់ ៥០៥ ដូចខាងក្រោម៖

> សំណួរ៖ *"ខ្ញុំទទួលបានជីវប្រវត្តិរបស់ប្តីអ្នកស្រី។ គាត់គឺជាសមាជិកនៃគណៈកម្មាធិការស្រុក ៥០៥ តើជាការត្រឹមត្រូវឬទេ?"*

---

[68] សំណុំរឿង ០០៣ ឯកសារ D114/170R, *CD ថតយកសំឡេងនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន* ថ្ងៃទី ១៥ កុម្ភៈ ឆ្នាំ ២០១៦។

[69] សំណុំរឿង ០០៣ ឯកសារ D59/1/3.51b *ជីវប្រវត្តិ ហ៊ួន យ៉េង* ដាក់នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣។

[70] ឯកសារ D114/184 កថាខណ្ឌ ២, ៣។

ចម្លើយទី៤៦៖ *"ចាស ត្រឹមត្រូវមែន"*។

សំណួរ៖ *"អ្នកស្រីឆ្លើយថា "មែន"។ តើអ្នកស្រីប្រាកដទេថាជាតំបន់ ៥០៥ ឬនេះគ្រាន់តែជាអ្វីដែលអ្នកស្រីចងចាំទេ?"*

ចម្លើយទី៤៧៖ *"ខ្ញុំចាំ។ រឿងនោះបានកើតឡើងជាច្រើនឆ្នាំមកហើយ ដូច្នេះខ្ញុំពិបាកចាំបានណាស់"*[71]។

59. ខ្ញុំបានពន្យល់នៅខាងលើរួចហើយថា ខ្ញុំមិនចាត់ទុកព័ត៌មានប្រភេទនេះជាព័ត៌មាន "សត្យានុម័ត" នោះទេ។ ផ្ទុយទៅវិញ ខ្ញុំចាត់ទុកព័ត៌មាននោះថាជាការសន្មត ដូចគ្នានៃការធ្វើទារុណកម្ម (និងហេតុដូចនេះមិនអាចទុកចិត្តបាន) ដែលភ្ជាប់ទៅនឹងចម្លើយសារភាពនៅមន្ទីរ ស-២១។ ទោះយ៉ាងណា ខ្ញុំមិនបានចាត់ទុកការស្តាប់ចម្លើយ កែវ សារួន ជាមោឃៈ និងដោយឈរលើមូលដ្ឋាននោះតែឯងនោះទេ។ ដូចដែលខ្ញុំបានពន្យល់នៅកថាខណ្ឌ ៣៥ ខាងលើ ផលប៉ះពាល់នៃឯកសារដែលមានការជាប់ពាក់ព័ន្ធកើតចេញពីជីវប្រវត្តិមានកម្រិតតិចជាង ប្រសិនបើខ្លឹមសារនៃការសួរចម្លើយមួយត្រូវបានប្រើប្រាស់ ហើយវាស្ថិតលើបរិមណ្ឌលនៃគោលនយោបាយការពារដែលជាមូលដ្ឋាននៃការប្រើប្រាស់ឯកសារ ដែលមានជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម។ ខ្ញុំក៏កត់សម្គាល់ឃើញផងដែរថា ផលប៉ះពាល់ដែលមានជាប់ទាក់ទងលើខ្លឹមសារនៃចម្លើយរបស់សាក្សី គឺតិចតួចណាស់ ហើយកំហុសនេះត្រូវបានកែប្រែយ៉ាងងាយស្រួលដោយមិនគិតដល់ចម្លើយទី ៤៦ រហូតដល់ចប់។ ខ្ញុំចាត់ទុកសំណើសុំមោឃភាព*តាមការផ្តួចផ្តើមផ្ទាល់ខ្លួន* អនុលោមតាមវិធាន ៧៦(១) នៃវិធានផ្ទៃក្នុង ថាមិនសមាមាត្រ និងមិនគោរពតាមចម្លើយទី ៤៦ រហូតដល់ចប់នៃឯកសារ D114/171 សម្រាប់ដំណាក់កាលបន្តទៀតនៃកិច្ចដំណើរការនីតិវិធីឡើយ។

## ឃ. សំណើទីពីរ

i. <u>ឯកសារដែលត្រូវបានបង្ហាញដល់សាក្សី</u>

[71] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ សារួន KH ERN 01204180 ឆ. ៤៦-ឆ. ៤៧។

60. ដូចដែលបានបង្ហាញខាងលើ[72] ឯកសារដែលបានបង្ហាញដល់សាក្សីក្នុងពេលវាយតម្លៃបឋមគឺជាជីវប្រវត្តិពីមន្ទីរ ស-២១ របស់ វ័ត្ន លាង។ ចំណុចនេះត្រូវបានកត់សម្គាល់ និងទទួលស្គាល់ដោយអ្នកស៊ើបអង្កេត និងសាក្សីនៅក្នុងការស្តាប់ចម្លើយនៅថ្ងៃបន្ទាប់[73]។

ii. <u>ថាតើអ្នកស៊ើបអង្កេតចេញហួសពីវិសាលភាពដែលមានការអនុញ្ញាតចំពោះការស្តាប់ចម្លើយត្រួតពិនិត្យដែរ ឬទេ</u>

61. ជាការប្រសើរ ខ្ញុំគិតថា អ្នកស៊ើបអង្កេតមិនគួរបង្ហាញជីវប្រវត្តិពីមន្ទីរ ស-២១ របស់ វ័ត្ន លាង ដល់សាក្សីនោះទេ។ គ្មានភាពចាំបាច់ត្រូវធ្វើដូច្នេះទេ។ ទោះយ៉ាងណា ការពិនិត្យឡើងវិញលើការថតសំឡេងនៃការស្តាប់ចម្លើយ និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីបានបង្ហាញថា ខ្លឹមសារក្នុងជីវប្រវត្តិពីមន្ទីរ ស-២១ មិនត្រូវបានពិភាក្សាជាមួយសាក្សីឡើយ។ ដូច្នេះ គ្មានមូលហេតុណាដែលត្រូវជឿថា ដោយការបង្ហាញជីវប្រវត្តិដល់សាក្សី អ្នកស៊ើបអង្កេតធ្វើឲ្យប៉ះពាល់ដល់ការស្តាប់ចម្លើយសាក្សីនោះទេ។

iii. <u>ការកំណត់ពេលវេលាពិភាក្សារបស់អ្នកស៊ើបអង្កេតជាមួយ ម៉ែន ផារី និង ឡុង ឡាញ</u>

62. អ្នកស៊ើបអង្កេតបាននិយាយជាមួយ ឡុង ឡាញ ដែលជាបងប្រុសចុងរបស់ វ័ត្ន លាង នៅថ្ងៃដដែលបាននិយាយជាមួយ ម៉ែន ផារី [74]។ ឡុង ឡាញ បានប្រាប់អ្នកស៊ើបអង្កេតថា ពួកគេត្រូវបានទទួលការចុះសួរសុខទុក្ខដោយអតីតកម្មាភិបាលជាន់ខ្ពស់ដែលបានប្រាប់ពួកគេថា មាស មុត បានបញ្ជាឲ្យចាប់ខ្លួន វ័ត្ន លាង និងបញ្ជូនទៅមន្ទីរ ស-២១[75]។

---

[72] *សូមមើលខាងលើ* កថាខណ្ឌ ៤៨។

[73] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែន ផារី KH ERN 01202829 ឆ. ៣; ប្រតិចារឹក ម៉ែន ផារី ទំព័រ ១១។

[74] ឯកសារ D114/174 ទំព័រ ៣។

[75] *ដូចជើងទំព័រខាងលើ*។

63. មេធាវីការពារក្តីព្យាយាមរកឲ្យឃើញថាតើ ឡុង ឡុញ បានឆ្លើយបែបនេះមុន ឬក្រោយពេល ម៉ែន ធារី ប្រាប់អ្នកស៊ើបអង្កេត ក្នុងអំឡុងពេលវាយតម្លៃបឋមនោះ ថា *"ម្តាយគាត់មានម្តង នោះប្រាប់គាត់ថា មាស មុត ជាអ្នកបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់ពួកគាត់"*[76]។

64. ការពិនិត្យឡើងវិញលើឯកសារ D114/174 បង្ហាញថា វាជាការមិនអាចទៅរួចទេក្នុងការបញ្ជាក់ឲ្យច្បាស់លាស់នូវពេលវេលានៃការផ្តល់ចម្លើយរបស់ ឡុង ឡុញ នេះ កុំថាឡើយថាតើគាត់ផ្តល់ចម្លើយនេះនៅចំពោះមុខ ម៉ែន ធារី ឬក៏អត់នោះ។ ទោះយ៉ាងណា ការពិតដែលថា របាយការណ៍របស់អ្នកស៊ើបអង្កេតក្នុងឯកសារ D114/174 ស្តីពីចម្លើយរបស់ ឡុង ឡុញ បន្ទាប់ពីគាត់រាយការណ៍អំពីទំនាក់ទំនងរបស់គាត់ជាមួយ ម៉ែន ធារី បង្ហាញ ខណៈពេលដែលខ្លឹមសារនៃឯកសារ D114/174 ផ្ទុយទៅវិញ សរសេរតាមលំដាប់កាលប្បវត្តិ ថា ឡុង ឡុញ បានផ្តល់ចម្លើយនេះ បន្ទាប់ពីអ្នកស៊ើបអង្កេតនិយាយជាមួយ ម៉ែន ធារី រួចហើយ។

iv. <u>ចម្លើយដែលបានផ្តល់អំពីជីដូន និងម្តាយរបស់សាក្សី</u>

65. ឯកសារ D114/174 អំពីសកម្មភាពកំណត់ហេតុសួរចម្លើយកត់ត្រាថា ម៉ែន ធារី បានឮអំពីវាសនារបស់ពួកគាត់ពី*ម្តាយ* របស់គាត់[77] ចំណែកឯកំណត់ហេតុស្តាប់ចម្លើយរបស់ ម៉ែន ធារី កត់ត្រាថា គាត់បានឮរឿងនោះពី*ជីដូន* របស់គាត់[78]។ នេះមិនមែនជាភាពមិនស្របគ្នានោះទេ។ ប្រតិចារិកនៃការថតសំឡេងនៃការសួរចម្លើយបញ្ជាក់ថា សាក្សីបានឮព័ត៌មានពីជីដូនរបស់គាត់[79] ដែលគាត់ក៏បានសំដៅដល់ផងដែរ នៅក្នុងការស្តាប់ចម្លើយដដែលនោះ ដោយពាក្យ "ម្តាយ" ឬ "ម៉ែ"[80]។ ដូច្នេះ ភ័ស្តុតាងដែលបានផ្តល់ឲ្យក្នុងការសួរចម្លើយនេះត្រូវបានកត់ត្រាយ៉ាងត្រឹមត្រូវក្នុងកំណត់ហេតុសួរចម្លើយ។ សាក្សីនេះទំនងជាបានប្រើពាក្យ "ម្តាយ" នៅពេលនិយាយប្រាប់ពីការដឹងពីវាសនារបស់ពួកគាត់ ដល់អ្នកស៊ើបអង្កេត ក្នុងពេលវាយតម្លៃ

---

[76] *ដូចជើងទំព័រខាងលើ*។ សំណើទីពីរ កថាខណ្ឌ ៨។

[77] ឯកសារ D114/174 ទំព័រ ៣។

[78] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែន ធារី KH ERN 01202830 ឆ. ១១។

[79] ប្រតិចារិក ម៉ែន ធារី កថាខណ្ឌ ១២, ២២, ២៤។

[80] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២២, ៤២។

បឋម ដែលហេតុនេះហើយទើបសកម្មភាពកំណត់ហេតុស្តាប់ចម្លើយ កត់ត្រាព័ត៌មានរបស់សាក្សីថាមកពីម្តាយរបស់គាត់។

66. ក្រុមមេធាវីការពារក្តីលើកឡើងថា ខ្សែអាត់ថតសំឡេងនៃការស្តាប់ចម្លើយបានបង្ហាញថា សាក្សីបានអះអាងថា អ្នកស៊ើបអង្កេតបានប្រាប់គាត់ថា មាស មុត ជាអ្នកទទួលខុសត្រូវចំពោះការស្លាប់របស់ពូគាត់ និងបានចោទប្រកាន់ថា ប្រការនេះមិនបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងកំណត់ហេតុស្តាប់ចម្លើយទេ[81]។

67. ប្រតិចារិកនៃការស្តាប់ចម្លើយបានកត់ត្រានូវកិច្ចសន្ទនាខាងក្រោមនេះ នៅពេលចាប់ផ្តើមការស្តាប់ចម្លើយ៖

| | |
|---|---|
| លោក Tedder [ភាសាអង់គ្លេស]៖ | *"ហើយកាលពីម្សិលមិញ ខ្ញុំបានប្រាប់អ្នក និងសាច់ញាតិរបស់អ្នកថាយើងបានកំណត់បានឈ្មោះមនុស្សម្នាក់ដែលមានឈ្មោះថា មាស មុត។ យើងបានបាន [ … ] ពីបទទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាច្រើនរួមទាំងការចាប់ខ្លួន និងបញ្ជូនបុគ្គលិកយោធាជាន់ខ្ពស់ទៅកាន់មន្ទីរ ស-២១"*។ |
| អ្នកបកប្រែ [ភាសាខ្មែរ]៖ | *"កាលពីម្សិលមិញ យើងក៏បានប្រាប់ក្រុមគ្រួសាររបស់អ្នកថា មាស មុត ជាអ្នកទទួលខុសត្រូវចំពោះការចាប់ខ្លួន បញ្ជូន* ***និងសម្លាប់*** *កម្មាភិបាល និងបញ្ជូនពួកគេទៅមន្ទីរសន្តិសុខទួលស្លែង។ តើជាការត្រឹមត្រូវឬទេ?"* (ការគូសបញ្ជាក់បន្ថែម) |
| ម៉ែន ធារី [ភាសាខ្មែរ]៖ | *"ចាស ត្រឹមត្រូវហើយ"* [82]។ |

68. នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ កិច្ចសន្ទនានេះត្រូវបានកត់ត្រាដូចខាងក្រោម៖

| | |
|---|---|
| សំណួរ៖ | *"តើអ្នកយល់ស្របទេថា កាលពីម្សិលមិញ យើងបានប្រាប់អ្នកថា មាស មុត ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មជាច្រើនរួមទាំងការចាប់ខ្លួន និងបញ្ជូនកម្មាភិបាលជាច្រើនទៅមន្ទីរ ស-២១?"* |

---

[81] សំណើទីពីរ, កថាខណ្ឌ ៦។

[82] ប្រតិចារឹក ម៉ែន ធារី កថាខណ្ឌ ១១-១២។

ចម្លើយទី៤៖ "ចាស"[83]។

69. ការយោងទៅដល់ការទទួលខុសត្រូវរបស់ មាស មុត ចំពោះ "ការសម្លាប់" ត្រូវបានដកចេញពីសំណួរទី៤ នៅក្នុងកំណត់ហេតុសួរចម្លើយ។ នៅចុងបញ្ចប់នៃការស្តាប់ចម្លើយ បន្ទាប់ពីការអានឡើងវិញបានបញ្ចប់ ប្រតិចារិកនៃខ្សែអាត់ថតសំឡេងនៃការស្តាប់ចម្លើយបានថតថា សាក្សីបានប្រាប់អ្នកបកប្រែថា គាត់បានចាំថាត្រូវបានគេប្រាប់ក្នុងអំឡុងពេលវាយតម្លៃ បឋមថា មាស មុត ជាអ្នកទទួលខុសត្រូវចំពោះការចាប់ខ្លួន និងការប្រហារជីវិត ឬការសម្លាប់មនុស្សនៅមន្ទីរ ស-២១[84]។ ទោះបីជាមានការបំភ្លឺពីសាក្សីបែបនេះក្តី ក៏កំណត់ហេតុស្តាប់ចម្លើយនេះមិនត្រូវបានកែប្រែដើម្បីរួមបញ្ចូលសេចក្តីយោងទៅ "ការសម្លាប់មនុស្ស" នៅក្នុងសំណួរទី៤ នោះទេ។

70. ថ្វីបើមានការខកខានក្នុងការធ្វើកែប្រែលើកំណត់ហេតុស្តាប់ចម្លើយ ដើម្បីឆ្លុះបញ្ចាំងពីការចងចាំរបស់សាក្សីចំពោះអ្វីដែលគាត់ត្រូវបានគេប្រាប់នៅក្នុងការវាយតម្លៃបឋមនេះក្តី ក៏ខ្ញុំមើលមិនឃើញពីការរើសអើងជាក់ស្តែងចំពោះ មាស មុត ដែលជាលទ្ធផលនៃការប្រឆាំងគ្នានេះ ដោយសារខ្ញុំគិតថា សាក្សីមានសមត្ថភាពផ្តល់ភ័ស្តុតាងស៊ីគ្នា និងឯករាជ្យពីការចងចាំរបស់គាត់ថាត្រូវបានគេប្រាប់ថា ពូគាត់ត្រូវបានសម្លាប់ដោយបុគ្គលដែលមានឈ្មោះថា "*មុត*"។ ជាពិសេស សាក្សីបានថ្លែងម្តងហើយម្តងទៀតថា គាត់ត្រូវបានប្រាប់ដោយជីដូនរបស់ខ្លួនថា ពូគាត់ត្រូវបានសម្លាប់ដោយមនុស្សម្នាក់ដែលមានឈ្មោះថា "*មុត*"[85]។ សាក្សីបានផ្តល់នូវភ័ស្តុតាងនៃកាលៈទេសៈជុំវិញការបង្ហាញនោះដោយជីដូនគាត់ និងមូលហេតុដែលគាត់បាននឹក

---

[83] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែន ធារី KH ERN 01202829 ឆ. ៤។

[84] ប្រតិចារឹក ម៉ែន ធារី កថាខណ្ឌ ៤៩-៥១។

[85] ប្រតិចារឹក ម៉ែន ធារី ទំព័រ ១២ (អ្នកបកប្រែ [ខ្មែរ]៖ *"នៅពេលយើងប្រាប់អ្នកពីឈ្មោះ "មាស មុត" អ្នកបានបង្ហាញពីចំណាប់អារម្មណ៍ និងបានប្រាប់ថាអ្នកឮឈ្មោះនេះពីជីដូនរបស់អ្នក។"* ម៉ែន ធារី [ខ្មែរ]៖ *"ចាស ជីដូនរបស់ខ្ញុំបានប្រាប់ខ្ញុំពីរឿងនេះ"*, ទំព័រ ១៤ (*"ខ្ញុំមិនដឹងថាត្រកូលរបស់គាត់ជាអ្វីនោះទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងគាត់ឈ្មោះ មុត គ្រាន់តែដឹងថាគាត់ឈ្មោះ មុត [...] ខ្ញុំមិនដឹងត្រកូលរបស់គាត់ទេនៅពេលនោះ។ គាត់និយាយតែពាក្យមួយម៉ាត់ប៉ុណ្ណោះ។"*), ទំព័រ ២២ (អ្នកបកប្រែ [ភាសាខ្មែរ]៖ *"តើអ្នកឮអ្វីខ្លះពីឈ្មោះ "មាស មុត" នៅពេលដំបូង?"* ម៉ែន ធារី [ភាសាខ្មែរ]៖ *"ខ្ញុំឮម្តាយរបស់ខ្ញុំថា" ពូរបស់ឯង ឈ្មោះលាងត្រូវបានគេសម្លាប់។ មុតជាឈ្មោះអ្នកដែលសម្លាប់។"*)

ឃើញពីការបង្ហាញនេះ[86]។ សាក្សីក៏ហាក់ដូចជាស្មោះត្រង់ចំពោះការទទួលស្គាល់នូវអ្វីដែលគាត់មិនបានដឹង[87]។ ប្រការទាំងនេះបង្ហាញថា ម៉ែន ធារី មានការចងចាំឯករាជពីអ្វីដែលជីដូនរបស់ខ្លួនបានប្រាប់នាងអំពីវាសនាពូរបស់គាត់ ហើយដូច្នេះភ័ស្តុតាងរបស់គាត់មុខជាមិនបានរងឥទ្ធិពលដោយសេចក្តីយោងទៅ "ការសម្លាប់មនុស្ស" ទេ។

vi. <u>សំណើសុំឱ្យកែប្រែកំណត់ហេតុនៃការស្តាប់ចម្លើយ</u>

71. ខ្ញុំបានលើកឡើងម្តងហើយម្តងទៀតថា វាជាការមិនសមរម្យទេដើម្បីកែប្រែកំណត់ហេតុស្តាប់ចម្លើយជាភាសាខ្មែរ ដោយសារថា វាបានបង្ហាញពីកំណត់ត្រាជាផ្លូវការនៃចម្លើយរបស់សាក្សីក្រោមការស្បថក្នុងអំឡុងការស្តាប់ចម្លើយរបស់តុលាការ ហើយកំណត់ហេតុស្តាប់ចម្លើយ ត្រូវបានចុះហត្ថលេខាលើគ្រប់ទំព័រដោយសាក្សី និងជនទាំងអស់ដែលមានវត្តមាននៅក្នុងការស្តាប់ចម្លើយនេះ[88]។ ក្នុងករណីណាក៏ដោយ ដូចមានចែងនៅកថាខណ្ឌមុន ខ្ញុំគិតថា មាស មុត មិនបានទទួលរងការរើសអើងជាក់ស្តែងណាមួយដែលជាលទ្ធផលនៃភាពខុសគ្នារវាងវិធីដែលសាក្សីត្រូវបានប្រាប់អំពីការទទួលខុសត្រូវ ដែលបានចោទប្រកាន់របស់ មាស មុត ក្នុងការវាយតម្លៃបឋម និងវិធីដែលចម្លើយត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយនោះទេ។ ហេតុនេះហើយបានជាខ្ញុំបដិសេធផ្នែកនេះនៃសំណើទីពីរ[89]។

**ផ្អែកលើហេតុផលដូចបានលើកឡើងខាងលើ ខ្ញុំសូម៖**

---

[86] *ដូចដើងទំព័រខាងលើ* ទំព័រ ២៤។ (ទាក់ទងនឹងការប្រទះឃើញជីដូនរបស់គាត់កំពុងតែយំ) ទំព័រ ២៦ (ឧទាហរណ៍ គាត់ចាំព្រោះគាត់ឃើញជីដូនរបស់គាត់យំតែពេលនោះប៉ុណ្ណោះ)។

[87] *ដូចដើងទំព័រ*ខាងលើ ទំព័រ ១៤។ (ឧទាហរណ៍ គាត់មិនដឹងឈ្មោះពេញរបស់ មាស មុតនោះទេ និងធ្លាប់ឮឈ្មោះ "មុត" ពីជីដូនរបស់គាត់) កថាខណ្ឌ ២៤-២៥ (ឧទាហរណ៍ គាត់មិនដឹងថាយាយរបស់គាត់ដឹងពីការស្លាប់របស់ពូគាត់ដោយរបៀបណានោះទេ)។

[88] សំណុំរឿង ០០៣ ឯកសារ D203/1 *ដីកាសម្រេចលើសំណើសុំឱ្យកែតម្រូវវិការៈក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយ* ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ កថាខណ្ឌ ១១-១២; សំណុំរឿង ០០៣ ឯកសារ D228/1 *សេចក្តីសម្រេចរបស់មាស មុត ទៅលើការកែតម្រូវឯកសារសំណុំរឿងជាក់លាក់* ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៧ កថាខណ្ឌ ៥។

[89] សំណើទីពីរ កថាខណ្ឌ ៨(ច)។

72. **ជូនដំណឹងដល់**មេធាវីការពារក្តីអំពីការឆ្លើយតបរបស់ខ្ញុំខាងលើទៅនឹងសំណួរដែលបានលើកឡើងក្នុងសំណើទីមួយ និងទីពីរ

73. **បដិសេធ** សំណើសុំកែប្រែកំណត់ហេតុស្តាប់ចម្លើយ របស់ ម៉ែន ធារី ដូចបានកំណត់ក្នុងកថាខណ្ឌ ៨ (ច) នៃសំណើទីពីរ

74. **ជូនដំណឹងដល់** ភាគីទាំងអស់ថា ខ្ញុំនឹងមិនយល់ស្របនឹងចម្លើយ ៤៦ នៃចម្លើយរបស់ កែវ សារួន (D114/171) ទេ និង

75. **ណែនាំឱ្យ** ក្រឡាបញ្ជីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដាក់ឯកសារដែលបានរាយនៅក្នុងឧបសម្ពន្ធនៃសេចក្តីសម្រេចនេះចូលក្នុងសំណុំរឿង ០០៣។

សេចក្តីសម្រេចនេះត្រូវបានដាក់ជាភាសាអង់គ្លេសជាមុន ហើយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់នៅពេលក្រោយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៧

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**Internationa Co-Investigating Judges**
**Co-juges d'instruction international**